**មាត្រា២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

===

# ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" អនុលោមតាមមាត្រា ៨៧ និងមាត្រា ៨៨ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា២ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវបានបង្កើតឡើងជាក្រុមប្រឹក្សាកំណែទំរង់មួយ នៅក្នុងឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ សំរាប់ផ្នែកជាអាតភាពនៃវិមជ្ឈការ ។

## ជំពូកទី ២

## បេសកកម្ម និង សមាសភាព

**មាត្រា៣ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល អំពីបញ្ហានានាដូចមានចែងក្នុងមាត្រា ៨៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបញ្ហាជាក់ស្តែងដែលមានជាអាទិ៍ :

-ការអនុវត្តន៏ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-កិច្ចការនានាដែលមានការប៉ះពាល់មកលើឃុំ សង្កាត់ លើកលែងតែកិច្ចការបោះឆ្នោត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ការរៀបចំ និងអនុវត្តគោលនយោបាយវិមជ្ឈការ ។

**មាត្រា៤ .-**

ផ្អែកតាមសមត្ថកិច្ចដូចបានចែងក្នុងមាត្រា ៣ ខាងលើនេះ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ មានភារកិច្ចជាក់ស្តែងដែលមានជាអាទិ៍ :

-ទំនាក់ទំង ពិភាក្សា និងសម្របសម្រួលជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងយន្តការកែទម្រង់រដ្ឋរបស់រាជរដ្ឋាភិបាល

-ធានាឱ្យមានការពិគ្រោះយោបល់ជាអន្តរក្រសួង និងការកសាងភាពជាដៃគូ ដើម្បីពិនិត្យមើលនូវបញ្ហា រួមសំដៅសំរេចអោយបាននូវកិច្ចព្រមព្រៀង ស្តីពីប្រតិបត្តិការ និងការទទួលខុសត្រូវរបស់ក្រសួងនីមួយៗ

-ពិនិត្យ និង រួមយោបល់លើខ្លឹមសារច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សារាចរ ដីកាខេត្ត ក្រុង និងកិច្ចព្រមព្រៀងដែលកំពុងស្ថិតនៅជាធរមាន ដើម្បីស្នើយោបល់អំពីការធ្វើវិសោធនកម្ម ឬ កែសំរួលឱ្យសមស្របសំរាប់គាំទ្រ ការអនុវត្តន៍នយោបាយវិមជ្ឈការ ។

-ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលមានការពាក់ព័ន្ធដល់ការងារឃុំ សង្កាត់ពិនិត្យផ្តល់យោបល់លើផែនការអភិវឌ្ឍន៍ កម្មវិធីអភិវឌ្ឍន៍ និងវិនិយោគ ព្រមទាំងសំណើអភិវឌ្ឍន៍ និងវិនិយោគពីប្រភពផ្សេងៗ ដែលមានការពាក់ព័ន្ធដល់ឃុំ សង្កាត់ និងទិដ្ឋភាពទាំងអស់នៃផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់

-សម្របសម្រួលដើម្បីឱ្យមានការអនុវត្តន៍ជាក់ស្តែងនូវហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និង សារពើពន្ធរបស់ឃុំ សង្កាត់

-សិក្សាស្រាវជ្រាវ និង កំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ និងការបង្កើតក្រុមប្រឹក្សា ឃុំ សង្កាត់រួមនៅពេលណាមួយសមស្រប

-សិក្សាអំពីកំណើនទីក្រុង និង នគរូបនីយកម្ម សំរាប់ជាមូលដ្ឋានបង្កើតគោលនយោបាយរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រទីក្រុងឱ្យបានសមស្រប

-សម្របសម្រួលដើម្បីឱ្យមានការអនុវត្តន៍ជាក់ស្តែងនូវមុខងារ និង អំណាចរបស់ឃុំ សង្កាត់រួម មានការផ្ទេរ (វិមជ្ឈការ) នៃមុខងារ "ផ្ទាល់ខ្លួន" និងប្រតិភូកម្ម (វិសហមជ្ឈការ) នៃមុខងារ "ជាភ្នាក់ ងារ" ពីរាជរដ្ឋាភិបាលទៅឃុំ សង្កាត់

-រៀបចំយុទ្ធសាស្ត្រនៃការផ្តល់ និងការចែកចាយសេវា រួមមានកិច្ចព្រមព្រៀងចែកចាយសេវា ការចាត់ចែងផ្តល់សេវា ក្នុងលក្ខណៈ សហប្រតិបត្តិការ ការធ្វើកិច្ចសន្យា និងលទ្ធកម្មរួមនៃអ្នកផ្តល់សេវា

-រៀបចំរចនាសម្ព័ន្ធរដ្ឋបាល និង យន្តការផ្តល់យោបល់នៃក្រុមប្រឹក្សាឃុំ សង្កាត់

-លើកកំពស់លទ្ធិប្រជាធិបតេយ្យ និងការគ្រប់គ្រងដោយមានការចូលរួមប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ

-រៀបចំក្រមសីលធម៌របស់សមាជិកក្រុមប្រឹក្សា និង មន្ត្រីដែលបំពេញការងារក្នុងឃុំ សង្កាត់

-កំណត់នូវទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់

-កំណត់អំពីគោលការណ៍ និង លក្ខខណ្ឌនៃការតែងតាំងបុគ្គលិកដោយក្រុមប្រឹក្សាឃុំ សង្កាត់

-ធ្វើការពិនិត្យតាមដាន ផ្តល់ការគាំទ្រខាងបច្ចេកទេស និងត្រួតពិនិត្យលើនីត្យានុកូលភាព ការងាររបស់ឃុំ សង្កាត់

-ធ្វើអន្តរាគមន៍ក្នុងនាមរាជរដ្ឋាភិបាល ទៅលើការគ្រប់គ្រងមិនស្របច្បាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងពិនិត្យសំរេចលើការព្យួរការរំសាយ ព្រមទាំងលើកសំណើឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនេះឡើងវិញ

-ចាត់វិធានការឱ្យមានការគ្រប់គ្រងបណ្តោះអាសន្នលើក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបំពេញភារកិច្ច ឬ អនុវត្តមុខងាររបស់ខ្លួន

-អប់រំ និង កសាងសមត្ថភាពធនធានមនុស្សរួមមាន ការបណ្តុះបណ្តាល ការរៀបចំកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និង មន្ត្រីដែលបានចាត់តាំង ។ រៀបចំកម្មវិធីតំរង់ទិស និង អប់រំដល់មន្ត្រីរាជការស៊ីវិលព្រមទាំងរៀបចំកម្មវិធីអប់រំ ដើម្បីមានការយល់ដឹងសំរាប់សាធារណជនទូទៅ

-ធ្វើការពិនិត្យតាមដាន និង វាយតម្លៃលើកិច្ចការនានា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

**មាត្រា៥** .-

គណៈកម្មាធិការនេះមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៥-រដ្ឋមន្ត្រីក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |

៦-រដ្ឋមន្ត្រីក្រសួងផែនការ ជាសមាជិក

៧-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក

៨-អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ ជាសមាជិក

**មាត្រា៦ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ចេញសេចក្តីសំរេច និង គោលការណ៍ណែនាំនានាផ្អែកតាមសមត្ថកិច្ចភារកិច្ចដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។

សេចក្តីសំរេច និង គោលការណ៍ណែនាំទាំងនោះ ត្រូវផ្អែកទៅលើឃុំ សង្កាត់ដែលមានធនធាន ឬមានសមត្ថកិច្ចហិរញ្ញវត្ថុ និងរដ្ឋបាលខុសគ្នា និងអាចរៀបចំជាដំណាក់កាល សំរាប់អនុវត្តបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា៧ .-**

ផ្អែកតាមសមត្ថកិច្ចរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ច ស្នើយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ស្របតាមនីតិវិធីជាធរមាន ។

**មាត្រា៨ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវបង្កើតកម្មវិធី យុទ្ធសាស្ត្រ និង គំរោងការងារ ព្រមទាំងក្របខ័ណ្ឌពេលវេលាសំរាប់អនុវត្ត ។

**មាត្រា៩ .-**

រយៈពេល ៦០ ថ្ងៃ មុនបញ្ចប់អាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល អំពីការអនុវត្តន៍បន្តទៀតនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ របៀបរបបការងារ និង លេខាធិការដ្ឋាន

**មាត្រា១០.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន ដើម្បីជាជំនួយការឱ្យខ្លួន ។

សមាសភាព និង មុខងារភារកិច្ចរបស់អនុគណៈកម្មការទាំងនោះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា១១ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំ និង អនុម័តនូវបទប្បញ្ញត្តិ ដែលកំណត់ពីនីតិវិធីប្រជុំ និង របៀបរបបធ្វើការងាររបស់ខ្លួន ព្រមទាំងអនុគណៈកម្មការចំណុះនានា ។

បទប្បញ្ញត្តិដែលកំណត់អំពីនីតិវិធីខាងលើនេះ ត្រូវអនុម័តដោយសម្លេងពីរភាគបី នៃសមាជិកទាំងមូលរបស់គណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា១២ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើអញ្ជើញរដ្ឋមន្ត្រីនៃក្រសួង ឬ ប្រធាន នៃស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬ ផ្តល់ពត៌មាន ឬ ផ្តល់កិច្ចសហការជួយដល់ការងាររបស់គណៈកម្មាធិការជាតិគ្រាំទ្រឃុំ សង្កាត់ ។

**មាត្រា១៣ ._**

អង្គភាពចំណុះក្រសួងមហាផ្ទៃ ទទួលការងាររដ្ឋបាលមូលដ្ឋាន ដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិគ្រាំទ្រឃុំ សង្កាត់ ។

ទីស្នាក់ការបំពេញការងាររបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុគណៈកម្មការ និងលេខាធិការដ្ឋានតាំងនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ ។

**មាត្រា១៤ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## ប្រភពធនធានថវិកា

**មាត្រា១៥ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវមានគំរោងថវិកាប្រចាំដើម្បីបំពេញការងារ ដោយដាក់បញ្ចូលក្នុងគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា១៦ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសំភារៈពីប្រភពក្នុងប្រទេស និងអន្តរជាតិសំរាប់គាំទ្រឃុំ សង្កាត់ និងសំរាប់អនុវត្តគោលនយោបាយវិមជ្ឈការ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចជួលអ្នកជំនាញការ អ្នកពិគ្រោះយោបល់ និង អ្នកបច្ចេកទេសជាតិ និង អន្តរជាតិ ។

ការសំរេចក្នុងការទទួលជំនួយខាងហិរញ្ញវត្ថុ សំភារៈ និង ការជួលអ្នកជំនាញការ អ្នកពិគ្រោះយោបល់ និង អ្នកបច្ចេកទេសជាតិ និង អន្តរជាតិ ត្រូវពិគ្រោះយោបល់ឯកភាពជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

នៅពេលចប់អាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ រាល់ចលនទ្រព្យ និង អចលនទ្រព្យត្រូវផ្ទេរទៅជូនក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៨ .-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង សមាសភាពដែលមានចែងក្នុងមាត្រា ៥ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១*

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

===